# ឃ្លាំមើលសភា តំណាងរាស្ត្រ

របាយការណ៍ឆ្នាំទី១ លេខ៨ | និតិកាលទី ៤ | ប្រចាំខែមិថុនា និងកក្កដា ឆ្នាំ ២០០៩


## មានការលំបាកទំនាក់ទំនង (Access) ជាមួយសមាជិករដ្ឋសភាតាមរយៈអគ្គលេខាធិការដ្ឋាន

ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលមួយចំនួនកំពុងជួបផលលំបាកក្នុងការផ្តល់ឯកសារ ឬលិខិតជូនតំណាងរាស្ត្រតាមរយៈអគ្គលេខាធិការដ្ឋានរដ្ឋសភា ដោយសារការផ្តល់ឯកសារដល់អ្នកតំណាងរាស្ត្រតាមរយៈរដ្ឋបាល ជាគោលការណ៍ត្រូវសុំការអនុញ្ញាតពីអគ្គលេខាធិការរដ្ឋសភា ហើយឯកសារមួយចំនួនមិនត្រូវបានដល់តំណាងរាស្ត្រនោះទេ ។

អ្នកតំណាងរាស្ត្រ **យឹម សុវណ្ណ** មណ្ឌលភ្នំពេញ អោយដឹងថា *"កន្លងមក ឯកសារខ្លះក៏បានទទួល ហើយ ខ្លះក៏មិនបានទទួល លុះត្រាតែមានគេទូរស័ព្ទប្រាប់ទើបដឹង"* ។ មិនអាចសុំការបំភ្លឺពីអគ្គលេខាធិការរដ្ឋសភាឯកឧត្តម ឡេង ប៉េងឡុង បានទេ ក៏ប៉ុន្តែអគ្គលេខាធិការរងរដ្ឋសភា ឯកឧត្តម **ហ៊ុល ប៊ុនថា** បានមានប្រសាសន៍ថា *"ការដាក់លិខិតផ្សេងៗគួរតែធ្វើបែបបទតាមនីតិវិធីដូចជា ការស្នើសុំទៅអគ្គលេខាធិការ បើអគ្គលេខាធិការសំរេចអោយដាក់ ទើបអាចដាក់បាន។ ព្រោះថាបើដាក់ទៅរដ្ឋបាលផ្ទាល់តែម្តង ខាងរដ្ឋបាលពុំហ៊ានសំរេចទេពីព្រោះថា មិនដឹងលិខិតអ្វី? ម្យ៉ាងទៀតរដ្ឋបាលក៏ទទួលបញ្ជាពីថ្នាក់លើដែរ ។"*

បន្ទាប់ពីការណែនាំរបស់រដ្ឋបាលនៃរដ្ឋសភា ការដាក់សំបុត្រ ឬឯកសារនានាត្រូវដាក់ក្នុងស្រោមសំបុត្រដើម្បីបញ្ជូនឯកសារទាំងនោះតាមរយៈរដ្ឋបាលរដ្ឋសភាទៅអ្នកតំណាងរាស្ត្រ។ បើទោះបីបានរៀបចំដូចនេះ ក៏មិនប្រាកដថា ឯកសារនៅក្នុងស្រោមសំបុត្រទាំងនោះបានទៅដល់ប្រអប់សំបុត្រតំណាងរាស្ត្រទាំង ១២៣ដែរ។ ជាក់ស្តែង ខុមហ្វ្រែល បានដាក់លិខិតជូនឯកឧត្តមអគ្គលេខាធិការរដ្ឋសភាចំនួន ២ដង រួចមកហើយកាលពីថ្ងៃទី **០៤ ខែ ធ្នូ ឆ្នាំ ២០០៨** និងថ្ងៃទី **២៩ ខែ មិថុនា ឆ្នាំ ២០០៩** ដើម្បីសុំដាក់លិខិត និងរបាយការណ៍ជូនតំណាងរាស្ត្រនីមួយៗតាមរយៈប្រអប់សំបុត្រតំណាងរាស្ត្រ។ ខុមហ្វ្រែល បានទាក់ទងរដ្ឋបាលសភាជាបន្តបន្ទាប់ ហើយចុងក្រោយនៅថ្ងៃទី **០៧ ខែ សីហា ឆ្នាំ ២០០៩** ប៉ុន្តែរដ្ឋបាលសភាបានឆ្លើយថា មិនឃើញមានការឆ្លើយតប ឬអនុញ្ញាតពីឯកឧត្តមអគ្គលេខាធិការឱ្យដាក់លិខិត/ឯកសារទាំងនោះក្នុងប្រអប់សំបុត្រតំណាងរាស្ត្រនោះទេ។

តំណាងរាស្ត្រ **អ៊ូ ច័ន្ទឫទ្ធិ** មណ្ឌលកណ្តាលបានមានប្រសាសន៍ថា រដ្ឋសភាមិនសូវមានការបើកចំហស្វាគមន៍ទទួលទំនាក់ទំនងពីខាងក្រៅទេ។ ជាក់ស្តែង ប្រជាពលរដ្ឋមិនអាចជួបតំណាងរាស្ត្ររបស់ខ្លួននៅការិយាល័យវិមានរដ្ឋសភាដែលខុសពីប្រទេសផ្សេងៗ។

តាមប្រព័ន្ធផ្សព្វផ្សាយរបស់វិទ្យុសំលេងប្រជាធិបតេយ្យផ្សាយនៅថ្ងៃទី ០១ សីហា ២០០៩ បានអោយដឹងថា និស្សិតប្រមាណ ១៥ នាក់ដែលស្នើសុំជួបតំណាងរាស្ត្ររបស់ខ្លួននៅក្នុងវិមានរដ្ឋសភា មិនត្រូវបានអគ្គលេខាធិការរដ្ឋសភាអនុញ្ញាតទេ ដោយសារគ្មានការអនុញ្ញាតពីប្រធានរដ្ឋសភា។

អ្នកតំណាងរាស្ត្រ **អ៊ូ ច័ន្ទឫទ្ធិ** ដែលក្រុមនិស្សិតចង់ចូលជួបដើម្បីសុំធ្វើទស្សនកិច្ចសិក្សានៅវិមានរដ្ឋសភាបានមានប្រសាសន៍ថា បានដាក់លិខិតនៅរដ្ឋសភាកាលពីខែ មេសា និងឧសភា ដើម្បីស្នើរដ្ឋសភាបង្កើតជាទស្សនៈកិច្ចសិក្សាមួយដើម្បីអោយប្រជាពលរដ្ឋអាចស្វែងយល់ពីការងារ និងតួនាទីរបស់រដ្ឋសភា ប៉ុន្តែពុំមានការឆ្លើយតបណាមួយពីសំណាក់រដ្ឋសភា។ នៅថ្ងៃទី ២៧ កក្កដា ២០០៩ អ្នកតំណាងរាស្ត្ររូបនេះបានដាក់លិខិតស្នើរសុំអគ្គលេខាធិការដ្ឋានរដ្ឋសភាដើម្បីអោយមានការអនុញ្ញាតិអោយនិស្សិតមួយក្រុមទៀតធ្វើទស្សនៈកិច្ចសិក្សាប៉ុន្តែត្រូវបានស្នើរអោយដាក់លិខិតសុំប្រធានរដ្ឋសភា ក៏ប៉ុន្តែក៏នូវតគ្មានការឆ្លើយតប។ រហូតដល់នៅថ្ងៃទី ៣១ កក្កដា ២០០៩ មាននិស្សិតប្រមាណ ១៥ នាក់បានធ្វើទស្សនកិច្ច

សិក្សានៅវិមានរដ្ឋសភា ប៉ុន្តែមិនត្រូវបានអនុញ្ញាតទេ រហូតដល់មានការតវ៉ាទើបសំរេចអោយចូលបាន ប៉ុន្តែត្រឹមតែការិយាល័យរបស់តំណាងរាស្ត្រ និងអាចទស្សនកិច្ចត្រឹមតែខាងក្រៅវិមានរដ្ឋសភា។

ទោះបីយ៉ាងណា អគ្គលេខាធិការរងរដ្ឋសភា ឯកឧត្តម **ហ៊ុល ប៊ុនថា** បានមានប្រសាសន៍ថាមិនបានដឹងរឿងនេះទេ ហើយបានបន្ថែមថា ប្រហែលជាលិខិតដែលបានដាក់ទៅអគ្គលេខាធិការ ប៉ុន្តែមិនមានការសំរេចពីប្រធានស្ថាប័ន។ ឯកឧត្តមបានមានប្រសាសន៍ថា តំណាងរាស្ត្រនីមួយៗ មានមណ្ឌលរបស់ខ្លួន។ ម្ចាស់ឆ្នោតនៅមណ្ឌលណាគួរទាក់ទងនៅមណ្ឌលនោះទៅ ព្រោះតាមមណ្ឌលនីមួយៗមានបុគ្គលិកប្រចាំការនៅទីនោះ ហើយបើប្រជាពលរដ្ឋមកដល់វិមានរដ្ឋសភាតែម្តងគឺមានការពិបាក ដូចជាអស់សោហ៊ុយច្រើន ហើយណាមួយស្ថាប័នរដ្ឋសភាជាកន្លែងតំណាងរាស្ត្រធ្វើការ។

ទោះបីយ៉ាងណា តាមការអង្កេតរបស់ ខុមហ្វ្រែល បង្ហាញថា តំណាងរាស្ត្រភាគច្រើនមានអស័យដ្ឋានរស់នៅភ្នំពេញ ហើយពេលចុះមូលដ្ឋានពុំសូវបានចូលការិយាល័យតំណាងរាស្ត្រនោះទេ ខណៈដែលការិយាល័យតំណាងរាស្ត្រក្នុងខេត្តមួយចំនួនមិនដំណើរការ ឬបុគ្គលិកធ្វើការ មិនតាមពេលវេលា។ មាត្រា ៧៧ នៃរដ្ឋធម្មនុញ្ញបានចែងថា *"តំណាងរាស្ត្រក្នុងរដ្ឋសភា ជាតំណាងប្រជាជាតិខ្មែរទាំងមូល ពុំមែនគ្រាន់តែជាតំណាងប្រជាពលរដ្ឋក្នុងមណ្ឌលរបស់ខ្លួននោះទេ។"*

អគ្គលេខាធិការដ្ឋានរដ្ឋសភា គឺជាកន្លែងផ្តល់សេវាដល់តំណាងរាស្ត្រ ហើយក៏ជាស្ពានសម្រាប់ភ្ជាប់តំណាងរាស្ត្រទៅនឹងម្ចាស់ឆ្នោតដែរ។ ដូចនេះអគ្គលេខាធិការដ្ឋានត្រូវបើកចំហដល់ប្រជាពលរដ្ឋម្ចាស់ឆ្នោត និងសម្រួលដល់ម្ចាស់ឆ្នោតក្នុងការទំនាក់ទំនងជាមួយតំណាងរាស្ត្រ ដូចមាត្រា ៣៥ នៃរដ្ឋធម្មនុញ្ញបានចែងថា *"សេចក្តីស្នើទាំងឡាយរបស់ប្រជាពលរដ្ឋ ត្រូវបានទទួលការពិនិត្យ និងដោះស្រាយយ៉ាងហ្មត់ចត់ពីអង្គការរដ្ឋ"* ហើយប្រការ ១៤ ថ្មីនៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភាចែងថា *"...អគ្គលេខាធិការដ្ឋាន [ រដ្ឋសភា ] នេះទទួលរ៉ាប់រងនូវគ្រប់កិច្ចការរដ្ឋបាល និងសេវានានាជូនរដ្ឋសភា និងគណៈកម្មការទាំងអស់ព្រមទាំងទំនាក់ទំនងផ្សេងៗក្រៅសភា ។"*

## ឆ្នាំទី ១ នៃនីតិកាលទី ៤ មានតំណាងរាស្ត្រ ៣ រូបត្រូវបានដកអភ័យឯកសិទ្ធសភា

អភ័យឯកសិទ្ធសភារបស់អ្នកតំណាងរាស្ត្រត្រូវបានដកជាបន្តបន្ទាប់តាមការស្នើសុំរបស់តុលាការនៅក្នុងបណ្តឹង ដែលកើតចេញពីការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រ បន្ទាប់ពីសភានីតិកាលទី ៤ បានចាប់ផ្តើមមិនទាន់បានមួយឆ្នាំផង ។

នៅថ្ងៃទី២២ ខែមិថុនា ដែលជាខែចុងក្រោយនៃសម័យប្រជុំលើកទី២ របស់រដ្ឋសភា មុនសម្រាកវិស្សមកាល រដ្ឋសភាជាតិបានបើកសម័យប្រជុំសម្ងាត់ ហើយអ្នកតំណាងរាស្ត្រដែលមកពីគណបក្សកាន់អំណាចប្រជាជនកម្ពុជា គណបក្សហ៊្វុនស៊ិនប៉ិច និងជាតិនិយម (អតីតគណបក្សនរោត្តរណឫទ្ធិ) បានបោះឆ្នោតដកអភ័យឯកសិទ្ធសមាជិកសភារបស់អ្នកតំណាងរាស្ត្រ ២រូប មកពីគណបក្សប្រឆាំងសមរង្ស៊ី តាមការស្នើសុំរបស់តុលាការដើម្បីចាត់វិធានការលើបណ្តឹងទាក់ទងនឹងបទបរិហារកេរ្តិ៍ ការញុះញង់ដែលកើតឡើងដោយសារការបញ្ចេញមតិ ក្រោយពីការដកអភ័យឯកសិទ្ធិសភារបស់អ្នកតំណាងរាស្ត្រ សម រង្ស៊ី កាលពីចុងខែកុម្ភៈ ។

ការដកអភ័យចុងក្រោយនេះទៅលើអ្នកតំណាងរាស្ត្រ មូរ សុខហួរ មណ្ឌលកំពត និងអ្នកតំណាងរាស្ត្រ ហូរ វ៉ាន់ មណ្ឌលភ្នំពេញត្រូវបានរិះគន់ពីអង្គការមិនមែនរដ្ឋាភិបាលក្នុងប្រទេស និងអន្តរជាតិមួយចំនួន ខណៈដែលអ្នកតំណាងរាស្ត្រទាំង ២រូប មិនត្រូវបានសភាអនុញ្ញាតឱ្យបញ្ចេញមតិឡើយនៅពេលមានការបោះឆ្នោតដកអភ័យឯកសិទ្ធិសភានោះ ។

អ្នកតំណាងរាស្ត្រ មូរ សុខហួរ បានចោទប្រកាន់ថា *"រដ្ឋសភាជារដ្ឋសភារបស់គណបក្សប្រជាជនកម្ពុជា ពួកគាត់ [អ្នកតំណាងរាស្ត្រប្រឆាំង] កំពុងត្រូវបានគេបិទសិទ្ធិសេរីភាពមិនឱ្យមានមតិយោបល់"* ។

ចំណែកអ្នកតំណាងរាស្ត្រ ហូរ វ៉ាន់ មានការហួសចិត្ត និងភ្ញាក់ផ្អើលយ៉ាងខ្លាំងដោយគាត់មិនគិតថា អភ័យឯកសិទ្ធិរបស់គាត់ត្រូវបានដកទេ ដោយសារតែរបៀបវារៈនៃការដកអភ័យឯកសិទ្ធិរបស់គាត់ទើបត្រូវបានប្រកាសឱ្យដឹងនៅថ្ងៃប្រជុំដកអភ័យឯកសិទ្ធិរបស់គាត់។ អ្នកតំណាងរាស្ត្ររូបនេះបានបន្ថែមថា *"ខ្ញុំមិនគិតថារឿងរបស់ខ្ញុំនឹងឈានដល់ការដកអភ័យឯកសិទ្ធិទេព្រោះខ្ញុំបានកែតម្រូវរួចរាល់អស់ហើយ។ គេមិនឱ្យខ្ញុំមានមតិយោបល់ជាលើកចុងក្រោយទេ មុននឹងឱ្យតំណាងរាស្ត្រលើកដៃដើម្បីដកអភ័យឯកសិទ្ធិខ្ញុំ"* ។

បន្ទាប់ពីការដកអភ័យឯកសិទ្ធិ សម្ព័ន្ធអង្គការសង្គមស៊ីវិលមួយចំនួនដែលធ្វើការអង្កេតលើសភា និងសិទ្ធិមនុស្សបានចេញសេចក្តីថ្លែងការរួមថា ដំណើរការព្យួរអភ័យឯកសិទ្ធិអ្នកតំណាងរាស្ត្រដោយសារតែបណ្តឹងបរិហារកេរ្តិ៍ និងការបញ្ចេញមតិបានធ្វើឱ្យប៉ះពាល់ដល់កិត្តិយសរបស់ប្រទេសកម្ពុជាក្នុងវិស័យអភិវឌ្ឍន៍ប្រជាធិបតេយ្យ និងពង្រឹងនីតិរដ្ឋនៅលើឆាកអន្តរជាតិ ។

ទោះបីយ៉ាងណា តំណាងរាស្ត្រគណបក្សកាន់អំណាច **ជាម យៀប** មណ្ឌលព្រៃវែងបានមានប្រសាសន៍ការពារចំពោះការដកអភ័យឯកសិទ្ធិសភានៅថ្ងៃប្រជុំរដ្ឋសភាពេញអង្គថ្ងៃទី២៣ ដោយចង់ឱ្យមានការឆ្លើយឆ្លងសួរដេញដោលដោយផ្ទាល់លើការចោទប្រកាន់លើរដ្ឋសភា។ អ្នកតំណាង-រាស្ត្ររូបនេះបានថ្លែងថា *"ខ្ញុំមានការសោកស្តាយណាស់ ខកចិត្តច្រើនណាស់ចំពោះរឿងម្សិលមិញ ដែលរដ្ឋសភាបានធ្វើសមស្របទៅតាមច្បាប់ដែលបានបញ្ញត្តិជាធរមាន ក្នុងនោះមានរដ្ឋធម្មនុញ្ញ១៩៩៣ ច្បាប់តំណាងរាស្ត្រ បទបញ្ជាផ្ទៃក្នុងដែលតំណាងរាស្ត្រអនុម័តដល់២/៣ យកធ្វើជាមូលដ្ឋាន។ ហើយមានបុគ្គលមួយចំនួនចេញទៅបិទមុខ បិទមាត់ ប្រាប់គេ ប្រាប់ឯងថារដ្ឋសភាផ្តាច់ការមិនគោរពច្បាប់។ សូមការអនុញ្ញាតពីសម្តេចប្រធាន មិនបាច់ចាត់តាំងអ្នកច្បាប់ណាទេ ខ្ញុំហ៊ានតទល់ជាមួយអ្នកដែលថា ដែលបានផ្សព្វផ្សាយនៅសន្និសីទកាសែត ឬមានជនបរទេស និងអង្គការក្រៅរដ្ឋាភិបាលមួយចំនួន ក៏បានស្រែកបន្តថា សភាផ្តាច់ការ មិនគោរពច្បាប់ទំលាប់។"*

ទោះបីយ៉ាងណា សង្គមស៊ីវិលបានលើកឡើងថា អភ័យឯកសិទ្ធិរបស់អ្នកតំណាងរាស្ត្រមកពីគណបក្សប្រឆាំងក្នុងអាណត្តិទី៤ នេះកំពុងស្ថិតនៅក្នុងភាពងាយស្រួលក្នុងការដកតាមការស្នើតាមរបស់តុលាការ ហើយរដ្ឋសភាបានត្រឹមពិចារណាលើទំរង់ច្បាប់ តែមិនពិចារណាលើគតិច្បាប់ដែលជាចំនុចសំខាន់សំរាប់ធ្វើការសំរេចចិត្ត ។

អ្នកតំណាងរាស្ត្រ មូរ សុខហួរ និងសម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** បានប្តឹងគ្នាទៅវិញទៅមកទៅកាន់តុលាការពីបទបរិហារកេរ្តិ៍។ ក៏ប៉ុន្តែបណ្តឹងរបស់អ្នកតំណាងរាស្ត្រ **មូរ សុខហួរ** ប្រឆាំងសម្តេច ហ៊ុន សែន ត្រូវបានតុលាការតំកល់ទុកឥតចាត់ការ ខណៈដែលបណ្តឹងរបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ត្រូវបានតុលាការបន្តចាត់វិធានការ និងស្នើសភាឱ្យដកអភ័យឯកសិទ្ធអ្នកតំណាងរាស្ត្ររូបនេះ។

អ្នកតំណាងរាស្ត្រ ហូរ វ៉ាន់ មកពីគណបក្សសមរង្ស៊ី ត្រូវបានក្រុមមន្ត្រីយោធាជាន់ខ្ពស់កម្ពុជា រួមទាំងឯកឧត្តម **ប៉ុល សារឿន** អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទផងដែរ បានចោទពីបទបរិហារកេរ្តិ៍ និងញុះញង់នៅពេលដែលអ្នកតំណាងរាស្ត្រ ហូរ វ៉ាន់ បានរិះគន់ពីសញ្ញាបត្រដែលមន្ត្រីជាន់ខ្ពស់នេះទទួលបានពីវិទ្យាស្ថានកងទ័ពជើងគោកវៀតណាម ។

នៅថ្ងៃទី ២៤ កក្កដា តុលាការក្រុងភ្នំពេញបានបើកសវនាការរបស់អ្នកតំណាងរាស្ត្រ មូរ សុខហួរ ដែលមានការចូលរួមអង្កេតពីខាងតំណាងរបស់សហភាពអន្តរសភា (IPU) ហើយសវនាការនោះអ្នកតំណាងរាស្ត្រ មូរ សុខហួរ មិនមានមេធាវីសំរាប់ការពារក្តីទេព្រោះមេធាវី គង់ សំអុន របស់គាត់បានសុំឈប់ការពារក្តីឱ្យអ្នកតំណាងរាស្ត្ររូបនេះ។

## រាជរដ្ឋាភិបាលមកបំភ្លឺសភាជាលើកទីមួយក្នុងនីតិកាលទី៤

តំណាងរាជរដ្ឋាភិបាលបានមកឆ្លើយបំភ្លឺសភាពេញអង្គជាលើកទីមួយក្នុងនីតិកាលទី៤នេះ តាមការស្នើសុំពីតំណាងរាស្ត្រ ខណៈដែលមានការស្នើសុំមកឆ្លើយបំភ្លឺចំនួនយ៉ាងតិចចំនួន ៥ដង ។

ឧបនាយករដ្ឋមន្ត្រី **សុខ អាន** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរអប្សរាដែលតំណាងឱ្យរាជរដ្ឋាភិបាលបានមកធ្វើការឆ្លើយបំភ្លឺសភាពេញអង្គស្តីពីការដាក់ភ្លើងបំភ្លឺប្រាសាទអង្គរវត្តនាពេលយប់ដ៏ចម្រូងចម្រាស តាមការស្នើសុំរបស់តំណាងរាស្ត្រ **កែ សុវណ្ណរតន៍** មណ្ឌលសៀមរាប។

នៅក្នុងការសួរ និងឆ្លើយឆ្លងដែលមានរយៈពេលពេញមួយព្រឹកនាថ្ងៃទី១៩ ខែមិថុនា មានតែតំណាងរាស្ត្រចំនួន ២រូបប៉ុណ្ណោះ មកពីគណបក្សជំទាស់បានលើកសំណួរ គឺអ្នកតំណាងរាស្ត្រ **កែ សុវណ្ណរតន៍** ឱ្យមានការបំភ្លឺជុំវិញការដាក់ភ្លើងហ្វាអគ្គិសនី ដោយមានការចោទថាខួងជញ្ជាំងថ្មប្រាសាទអង្គរវត្ត ហើយអ្នកតំណាងរាស្ត្រ **សុន ឆ័យ** មណ្ឌលភ្នំពេញ បានស្នើឱ្យឯកឧត្តម **សុខ អាន** បំភ្លឺជុំវិញការងារនៃអាជ្ញាធរអប្សរា។

ឯកឧត្តម សុខ អាន បានធ្វើការបំភ្លឺថា *"ប្រទេសណាក៏មានការតាំងលំអអំពូលលើបេតិកភណ្ឌដ៏មានតំលៃរបស់ខ្លួនគេនេះដែរ... វាមិនមានការប៉ះពាល់អ្វីទេ។ ការដាក់អំពូលនេះជាបច្ចេកវិទ្យាថ្មី មានរោងចក្រតិចណាស់ដែលផលិតអំពូលនេះ ហើយហេតុនៃការដាក់អំពូល នេះព្រោះតែលំអលើកកំពស់សម្បត្តិវប្បធម៌របស់ជាតិ ផ្តល់ជូនទេសចរណ៍ដែលអាចមកទស្សនាពេលយប់ ពង្រីងការងារ ទេសចរណ៍យើងដើម្បីកុំឱ្យប៉ះពាល់សេដ្ឋកិច្ច ហើយម្យាងរន្ធសំរាប់ដាក់អំពូលមានស្រាប់*[មិនមានការខួងរន្ធនោះទេ] *។"*

ទោះបីយ៉ាងណា ឯកឧត្តម **សុខ អាន** បានមានប្រសាសន៍ថា "[ការដាក់អំពូល] *ជាដំណាក់កាលសាកល្បងមើលពន្លឺបណ្តោះអាសន្នទេ ហើយអំពូលដែលដាក់នោះគឺទិញពីផ្សារយើងទេ មិនមែនជាអំពូលដែលខាងអាជ្ញាធរអប្សរាកុម្ម៉ង់ពីរោងចក្រផលិតអំពូលនោះទេ។"*

គួររំលឹកផងដែរថា ការដាក់អំពូលភ្លើងនៅប្រាសាទអង្គរវត្តបានបង្កភាពចម្រូងចម្រាសយ៉ាងខ្លាំង ដោយប្រព័ន្ធផ្សព្វផ្សាយមួយចំនួនបានរាយការណ៍ពីការសង្ស័យថា បានដាប់ថ្មប្រាសាទអង្គរវត្តដើម្បីបានរន្ធដាក់អំពូល។ ក្រោយពីមានការផ្សព្វផ្សាយពីបណ្តាញព័ត៌មាន ទើបឃើញមានប្រតិកម្មពីអាជ្ញាធរអប្សរា និងមានការធ្វើសន្និសីទសារព័ត៌មានបកស្រាយបំភ្លឺចំពោះការដាក់អំពូលនេះ។ ទោះបីយ៉ាងណា រឿងដ៏ចម្រូងចម្រាសនេះបានធ្វើឱ្យរាជរដ្ឋាភិបាលកម្ពុជាប្តឹងប្រធានអង្គការមូលនិធិទ្រទ្រង់អរិយធម៌ខ្មែរ លោក **មឿង សុន** ពីបទផ្សព្វផ្សាយព័ត៌មានមិនពិតទាក់ទងនឹងការដាក់អំពូលភ្លើងបំភ្លឺប្រាសាទអង្គរវត្ត ហើយត្រូវបានតុលាការកាត់ទោសឱ្យជាប់ពន្ធនាគារចំនួន ២ឆ្នាំ និងបង់ប្រាក់ពិន័យចំនួន ១៥ លាន រៀល។